ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

លេខ ៣៣៧ សករបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០២

## ប្រកាស

## ស្តីពី

## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី០៩ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ/បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០២ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករប្រចាំឆ្នាំ២០០៣។

## សំរេច

**ប្រការ១:**- ថ្ងៃបុណ្យដែលត្រូវឈប់ ហើយបានប្រាក់ឈ្នួលនៅ ឆ្នាំ ២០០៣ សំរាប់កម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារត្រូវបានកំណត់ដូចតទៅ:-

- បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែមករា
- បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា
- បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា
- បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី ១៤ ១៥ និងថ្ងៃទី ១៦ ខែ មេសា

- បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ ឧសភា
- បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ១៥ ខែ ឧសភា
- ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ១៩ ខែ ឧសភា
- បុណ្យទិវាកុមារអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០២ ខែ មិថុនា ជំនួសថ្ងៃទី ០១ ខែ មិថុនា ដែលចំថ្ងៃអាទិត្យ
- ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុចំនួនមួយថ្ងៃគឺថ្ងៃទី ១៨ ខែមិថុនា
- បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ចំនួនមួយថ្ងៃ គឺថ្ងៃទី ២៤ ខែ កញ្ញា
- បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ២៤ ២៥ និងថ្ងៃទី ២៦ ខែ កញ្ញា
- បុណ្យទិវាសិទ្ធិសញ្ញាសន្តិភាពក្រុងប៉ារីសចំនួនមួយថ្ងៃ គឺថ្ងៃទី ២៣ ខែ តុលា
- ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុចំនួនបីថ្ងៃ គឺនៅថ្ងៃទី ៣០ ៣១ ខែ តុលា និងថ្ងៃទី ០១ ខែ វិច្ឆិកា
- ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុកចំនួនបីថ្ងៃ គឺនៅថ្ងៃទី ០៧ ០៨ និងថ្ងៃទី ១០ ខែ វិច្ឆិកា ជំនួសថ្ងៃទី ០៩ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ
- បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ១០ ខែវិច្ឆិកា ជំនួសថ្ងៃទី ០៩ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ
- បុណ្យទិវាសិទ្ធិមនុស្សចំនួនមួយថ្ងៃ គឺថ្ងៃទី ១០ ខែ ធ្នូ ។

**ប្រការ២**.- ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា ១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវអោយឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករ និយោជិតទាំងអស់ ។

**ប្រការ៣**.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"